# ស្ថាប័នអប់រំយុវជនខ្មែរ

# (K. C. E. O.)

## សារតារៈ

នៅឆ្នាំ២០០៥ គ្រាដែលលោកហ៊ិមម៉ារិនបានប្រឡងជាប់បរិញ្ញាត្រីផ្នែក“គ្រប់គ្រងទូទៅ” នៅសាកលវិទ្យាល័យទីក្រុងភ្នំពេញ រួចវិលត្រឡប់មកកាន់ស្រុកកំណើតវិញទាំងមានគោលបំណង ផ្តល់នូវការរីកចំរើនក្នុងសហគមន៍ ជាពិសេសខាងវិស័យសិក្សា។ ប៉ុន្តែដោយមានកង្វះខាតថវិកាហើយនិងសម្ភារៈ គំរោងនេះក៏ត្រូវពន្យារពេលមកដល់ឆ្នាំ២០០៨។ លោកហ៊ិមម៉ារិនបានចាប់ផ្តើមបង្រៀនភាសាអង់គ្លេសនៅឆ្នាំ២០០៥ នៅក្រោមដើមឈើនៅភូមិករបស់លោក ហើយមានសិស្ស៤៥នាក់ ស្រី១៦នាក់ ប្រុស២៩នាក់។ ចំនួន៦០ភាគរយមកពីគ្រួសារទាល់ក្របំផុត។ ចាប់តាំងពីពេលនោះមកឪពុកម្តាយនិងអ្នកផ្តល់អំណោយ ក៏កាន់តែមានច្រើនឡើងព្រោះទុកចិត្តថា លោកម៉ារិននឹងផ្តល់នូវមុខវិជ្ជាជីវៈសំខាន់ៗតាមបរិដ្ឋានក្រៅផ្លូវការនេះ។ គេនាំយកកូនមកចូលរៀនច្រើនឡើងៗពីព្រោះគេសំគាល់ឃើញ កត្តាសំខាន់៣នៃថ្នាក់រៀនលោកម៉ារិនៈ

១. សិស្សដែលឪពុកម្តាយទីទាល់បំផុត មិនចាំបាច់បង់ថ្លៃទេ។
២. សិស្សទាំងនោះរួមបញ្ចូលសិស្សដែលបានសិក្សានៅវិទ្យាល័យ ឬបានប្រឡងជាប់កម្មវិធីសិក្សាជាន់ខ្ពស់ ព្រមទាំងជាយុវសិស្សនៅក្នុងសហគមន៍។
៣. សិស្សទាំងនោះបានទទួលមុខវិជ្ជាសិក្សា និងវិជ្ជាជីវៈដោយមិនចាំបាច់បង់ថ្លៃរៀនច្រើន។

នៅឆ្នាំ២០១០ អ្នកគ្រប់គ្រងក្នុងតំបន់និងភ្នាក់ងារខាងច្បាប់ បានឆ្លើយតបទៅនឹងទស្សនៈលោកម៉ារិន ដោយបន្ថែមនូវវិស័យសិក្សាតាមបែបតាមទម្លាប់ ជាមួយនឹងកម្មវិធីក្រោយម៉ោងសិក្សា។ ដោយអនុលោមតាមនេះ លោកម៉ារិនចាំបាច់ត្រូវធ្វើឲ្យទៅជាស្ថាប័នសិក្សាពេញលក្ខណៈច្បាប់។ លោកបានរិះរកថវិកាចាំបាច់ មានទាំងលក់ក្របីដើម្បីបង់ថ្លៃដាក់ពាក្យសុំNGOពេញលក្ខណៈច្បាប់ ព្រមទាំងបរិច្ចាគកម្មសិទ្ធិរបស់

គ្រួសារផ្ទាល់មួយចំណែក ដើម្បីនឹងបង្កើតស្ថាប័នអប់រំយុវជនខ្មែរ(K. C. E. O.) ។ ស្ថាប័ននេះធ្វើឲ្យលោកអាចបង្កើនប្រសិទ្ធិភាពនៃកម្មវិធីសិក្សា សំរាប់យុវជនជាច្រើនទៀតដែលមកពីសហគមន៍ជុំវិញ។

នៅថ្ងៃទី៣ខែមករាឆ្នាំ២០១២ ពាក្យដាក់សុំនោះត្រូវបានយល់ព្រម រួចអនុញ្ញាតឲ្យបើកស្ថាប័នប្រចាំតំបន់មួយ អំពីប្រធានភូមិប្រធានសង្កាត់ហើយនិងអភិបាលស្រុក។ ដល់ថ្ងៃទី២៦ខែមិនាឆ្នាំ២០១២ ក៏បានទទួលលក្ខណៈពេញច្បាប់ជាNGO ហៅថា ស្ថាប័នអប់រំយុវជនខ្មែរ(K. C. E. O.) ព្រមទាំងបានលិខិតអនុញ្ញាតឲ្យមានដំណើរការស្ថាប័នអប់រំយុវជន។ នៅថ្ងៃទី២៥ខែឧសភាឆ្នាំ២០១២ មានខ្មែរមកពីលោកអភិ-បាលខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្ននេះ ស្ថាប័នអប់រំយុវជនខ្មែរមានបុគ្គលិកអចិន្ត្រៃយ៍៨នាក់ ចំណោមនោះ៥នាក់ជាស្ត្រី។

**ទស្សនៈ**

ស្ថាប័នអប់រំយុវជនខ្មែរ(K. C. E. O.) មានគោលបំណងនឹងជួយក្មេងៗពួកវ័យជំទង់ ជាពិសេសយុវជនទន់ខ្សោយ ឲ្យមានចំណេះដឹងនិងវិជ្ជាជីវៈ ប្រយោជន៍ឲ្យអាចផ្គត់ផ្គង់ខ្លួនឯងបាន ហើយនិងជួយដល់សហគមន៍ដែលខ្លួនរស់នៅ។